# ប្រកាសអន្តរក្រសួង
# ស្តីពីការចុះបញ្ជីអចនលវត្ថុ
# ទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ក្រសួងយុត្តិធម៌**

លេខ : ០៥ ប្រក.ដ.ន.ស/១១

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៤៦អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- តាមការចាំបាច់ក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ : គោលដៅ**

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីអចលនវត្ថុឱ្យបានត្រឹមត្រូវទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ២ : គោលបំណង**

១-ប្រកាសនេះ បញ្ញត្តអំពីនីតិវិធីនៃការផ្ទុកផ្តាក់របស់ក្រឡាបញ្ជី ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូស ការផ្ទេរ ការលុបចោល ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី និងនីតិវិធីនៃការចុះបញ្ជីទាំងនោះ ។

២-ប្រកាសនេះ ក៏បញ្ញត្តផងដែរអំពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុតាមរយៈ សាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ យោងតាមមាត្រា ៥២៩ (ការចាត់ទុកថាបានបង្ហាញឆន្ទៈ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ៣ : វិសាលភាព**

ប្រកាសនេះ ត្រូវយកមកអនុវត្ត ចំពោះដីដែលកម្មសិទ្ធិត្រូវបានចុះបញ្ជី ក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយដែលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រូវបានចេញ ។

ប្រកាសនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីដែលត្រូវបានចុះបញ្ជី ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ហើយដែលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីត្រូវបានចេញ ។

**ប្រការ ៤ : ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី**

ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីតាមន័យនៃប្រកាសនេះ គឺរដ្ឋបាលសុរិយោដីដែលបានកំណត់ដូចខាងក្រោមនេះ :

-ចំពោះការចុះបញ្ជីដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ នៃប្រការ ២ (គោលបំណង)

ក្រឡាបញ្ជីត្រូវផ្ញើលិខិតផ្ទុកផ្តាក់ទៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត

-ចំពោះការចុះបញ្ជីដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ២ នៃប្រការ ២ (គោលបំណង) ភាគីឈ្នះក្តី ឬ ភាគីដែលមានកំណត់ហេតុសះជា ឬ កំណត់ហេតុទទួលស្គាល់នូវការទាមទារត្រូវដាក់ពាក្យសុំទៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត ដែលអចលនវត្ថុដែលត្រូវចុះបញ្ជីតាំងនៅ ឬ រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ។

## ជំពូកទី ២
## ការចុះបញ្ជីតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី

### ផ្នែកទី ១
### ទម្រង់ និងឯកសារភ្ជាប់ នៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី

**ប្រការ ៥ :** ទម្រង់នៃលិខិតផ្ទុកផ្តាក់

លិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជីទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ឈ្មោះតុលាការ លេខលិខិតផ្ទុកផ្តាក់ ឈ្មោះក្រឡាបញ្ជី កាលបរិច្ឆេទ ហត្ថលេខា និងបោះត្រារបស់ក្រឡាបញ្ជី ។ ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃលិខិតផ្ទុកផ្តាក់ ដូចមានចែងក្នុងផ្នែកទី ២ (ប្រភេទនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី) នៃជំពូកទី ២ (ការចុះបញ្ជីតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី) នៃប្រកាសនេះ ដោយមានបង្ហាញនៅក្នុងគំរូឧបសម្ព័ន្ធទៅតាមប្រភេទនៃលិខិតផ្ទុកផ្តាក់នីមួយៗ ។

**ប្រការ ៦ :** ឯកសារភ្ជាប់ជាមួយលិខិតផ្ទុកផ្តាក់

នៅពេលប្រគល់លិខិតផ្ទុកផ្តាក់ ក្រឡាបញ្ជីត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនទៅឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីទៅតាមប្រភេទនៃលិខិតផ្ទុកផ្តាក់ ដូចមានចែងក្នុងផ្នែកទី ២ (ប្រភេទនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី) នៃជំពូកទី ២ (ការចុះបញ្ជីតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី) នៃប្រកាសនេះ ។

# ផ្នែកទី ២

## ប្រភេទនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី

## កថាភាគទី ១

## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

**ប្រការ ៧ :** លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយផ្អែកលើមាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

នៅពេលដែលតុលាការអនុវត្ត ចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តចំពោះអចលនវត្ថុ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ។

បើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានចេញរួចហើយ តែមានពាក្យសុំអនុវត្តដោយបង្ខំថ្មីមួយទៀត ចំពោះអចលនវត្ថុដដែលនោះ ហើយតុលាការបានទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំថ្មីមួយទៀត (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ចធ្វើការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ។

ចំពោះការចុះបញ្ជីដូចមានចែងនៅក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការ ៧ (លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ) នេះ លិខិតផ្ទុកផ្តាក់នៅក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ :....................(សរសេរអំពីខ្លឹមសារនៃការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ...................................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគីនៃអចលនវត្ថុ..........(អាសយដ្ឋាន....................)

គ-គោលបំណងនៃការចុះបញ្ជី...................................(រឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ចំណុច "ក")

ឃ-មូលហេតុ..............................(ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ

លេខ.......ចុះថ្ងៃទី......ខែ.....ឆ្នាំ......និងឈ្មោះរបស់តុលាការ............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត......................(អាសយដ្ឋាន..............
...............................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត........................(អាសយដ្ឋាន...............
...............................)

ព្រមទាំងភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូត នៃដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំផង ដែរ ។

## ប្រការ ៨ : លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បើពាក្យសុំឱ្យលក់ដោយបង្ខំត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោល នីតិវិធីលក់ដោយបង្ខំបានកើតឡើងទៅលើអចលនវត្ថុដែលត្រូវរឹបអូស ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័ន មានសមត្ថកិច្ចឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ហើយលិខិតផ្ទុកផ្ដាក់នៅក្នុងវាក្យខណ្ឌ ទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:.....................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស អចលនវត្ថុ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.............................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ (អាសយដ្ឋាន....................................................)

គ-គោលបំណងនៃការចុះបញ្ជី................. (លុបការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ចំណុច “ក” )

ឃ-មូលហេតុ...................(ពាក្យសុំលក់ដោយបង្ខំត្រូវបានដកចេញ ចុះថ្ងៃទី..... ខែ........ឆ្នាំ......... ឬដីកាសម្រេចឱ្យលុបចោលនីតិវិធីលក់ដោយបង្ខំលេខ.......ចុះថ្ងៃទី...... ខែ.......ឆ្នាំ........ ហើយថ្ងៃទី....ខែ........ឆ្នាំ......... ដែលដីកាសម្រេចមានអានុភាព និង ឈ្មោះរបស់តុលាការ..............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន.............
.............................)

ច-ឈ្មោះភ្នំពេញបំណុលនៃការអនុវត្ត........................(អាសយដ្ឋាន............
..............................) ។

ឯកសារភ្ជាប់ជាមួយ ៖

១-ក្នុងករណីមានការដកពាក្យសុំឱ្យលក់ដោយបង្ខំ ៖

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំមានអានុភាព ៖

ក-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ។

ខ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៣៧៥ (ការបង់សោហ៊ុយជាមុន) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជី ថាបានចូលជាស្ថាពរ ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ជាអាទិ៍ នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

ឃ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៤៣៥ (វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

ង-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ៤ នៃមាត្រា ៤៤៣ (វិធានការក្នុងករណីលក់ហួសកម្រិត) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

**ប្រការ ៩ :** លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការផ្ទេរផលុបភោគ តាមការលក់ដោយបង្ខំ ដោយផ្អែកលើមាត្រា ៤៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគដែលអ្នកទិញបានធ្វើលទ្ធកម្ម និងឱ្យលុបការចុះបញ្ជីដោយត្រូវ :

១-ផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

២-ផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

៣-ផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ។

៤-ផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬការរឹបអូសជាបណ្តោះអាសន្ន ។

ចំពោះលិខិតផ្ទុកផ្តាក់នៅក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ :.......................................(សរសេរអំពីខ្លឹមសារនៃការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី )

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ (អាសយដ្ឋាន ........................................)

គ-គោលបំណងនៃការចុះបញ្ជី :

-ផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ តាមការលក់ដោយបង្ខំទៅអោយឈ្មោះ......................

-លុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ទៅលើចំណុច "ក"

-លុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ទៅលើចំណុច "ក"

-លុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន ទៅលើចំណុច"ក" ។

ឃ-មូលហេតុ :

-ដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........ចុះថ្ងៃទី.....ខែ......ឆ្នាំ......និងឈ្មោះរបស់តុលាការ...................................

-អ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ...............នៅថ្ងៃទី.....ខែ.....ឆ្នាំ.....។

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.........................(អាសយដ្ឋាន.............................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន............................................)

ឆ-អត្តសញ្ញាណអ្នកទិញ.................(ថ្ងៃទី......ខែ.......ឆ្នាំ.......ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ អាសយដ្ឋាន............................ របស់អ្នកទិញ) ។

ឯកសារភ្ជាប់ជាមួយ:

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឱ្យលក់

-ឯកសារថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទិញ

-ឯកសារចម្លងយថាភូតនៃកំណត់ហេតុដែលបញ្ជាក់ថា អ្នកទិញបានបង់ថ្លៃលក់ទៅតុលាការអនុវត្តរួចហើយ ។

## កថាភាគទី ២

## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

**ប្រការ ១០ :** លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ **ដោយផ្អែកលើមាត្រា ៤២០ មាត្រា ៥១១ និងមាត្រា ៥១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

នៅពេលដែលតុលាការអនុវត្តចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមាន

សមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគនោះ ។

បើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានចេញរួចហើយ តែមានពាក្យសុំអនុវត្តសិទ្ធិប្រាតិភោគថ្មីមួយទៀត ចំពោះអចលនវត្ថុដដែលនោះ ហើយតុលាការបានទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំថ្មីមួយទៀត (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ញើកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ច ធ្វើការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយអនុវត្តសិទ្ធិប្រាតិភោគ ។

ចំពោះការចុះបញ្ជីដូចមានចែងនៅក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការ ១០ (លិខិតផ្ញើកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ) នេះ លិខិតផ្ញើកផ្តាក់ក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ញើកផ្តាក់) ត្រូវសរសេរបន្ថែម នូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ: ........................(សរសេរអំពីខ្លឹមសារការផ្ញើកផ្តាក់ចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ..........................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី )

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ.......... (អាសយដ្ឋាន ..............................................)

គ-គោលបំណងនៃការចុះបញ្ជី...............................(រឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ចំណុច "ក" )

ឃ-មូលហេតុ......................(ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ..... ចុះថ្ងៃទី.....ខែ.....ឆ្នាំ.......និងឈ្មោះរបស់តុលាការ............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន............... ..................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន.............. ..................................)

ព្រមទាំងភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូត នៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំផងដែរ ។

**ប្រការ ១១ : លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ បានកើតឡើងទៅលើការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ហើយលិខិតផ្ទុកផ្ដាក់នៅក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:......................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ.............. (អាសយដ្ឋាន.........................................)

គ-គោលបំណងនៃការចុះបញ្ជី..........................(លុបការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុចំណុច "ក" )

ឃ-មូលហេតុ...............(ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុត្រូវបានដកចេញ ចុះថ្ងៃទី......ខែ.........ឆ្នាំ......... ឬ ដីកាសម្រេចឱ្យលុបចោលនីតិវិធីលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី.....ខែ........ឆ្នាំ........... ហើយថ្ងៃទី......ខែ........ឆ្នាំ........ ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ.............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន............... .........................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន................ .........................................)

ឯកសារភ្ជាប់ជាមួយ:

១-ក្នុងករណីមានការដកពាក្យសុំការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹម

ត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំ ធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ មានអានុភាព :

ក-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រា ៤៩៨ (ការផ្អាក និងការលុបចោលការអនុវត្តសិទ្ធិប្រាតិភោគ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ។

ខ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៣៧៥(ការបង់សោហ៊ុយជាមុន) ក្រឡាបញ្ជីត្រូវភ្ជាប់នូវលិខិតចម្លងយថាភូតនៃដីកាសម្រេចលុបចោល ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ជាអាទិ៍នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធី ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

ឃ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៤៣៥ (វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់)ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ។

ង-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ៤ នៃមាត្រា ៤៤៣ (វិធានការក្នុងករណីលក់ហួសកម្រិត) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

**ប្រការ ១២ : លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគតាមការអនុវត្តសិទ្ធិប្រាតិភោគដោយផ្អែកលើមាត្រា ៤៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម និងឱ្យលុបការចុះបញ្ជី ។ ប៉ុន្តែក្នុងករណីអ្នកទិញជាអ្នកធានាដោយវត្ថុ ដែលជាម្ចាស់សិទ្ធិដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ ក្រឡាបញ្ជីមិនចាំបាច់ធ្វើការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគទេ ។

ចំណុចដែលត្រូវផ្ទុកផ្ដាក់ឱ្យចុះបញ្ជីផ្ទេរសិទ្ធិ និងឱ្យលុបការចុះបញ្ជីគឺ :

១-ផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

២-ផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

៣-ផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ។

៤-ផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ :.....................(សរសេរអំពីខ្លឹមសារនៃការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន )

ក-អត្តសញ្ញាណនៃអចលនវត្ថុ............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ (អាសយដ្ឋាន..............................................)

គ-គោលបំណងនៃការចុះបញ្ជី :

-ផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ តាមការលក់ដោយបង្ខំទៅឱ្យឈ្មោះ ...................................

-លុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ទៅលើចំណុច “ក”

-លុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ទៅលើចំណុច “ក”

-លុបការចុះបញ្ជីអំពីការរឹបអូស ឬការរឹបអូសជាបណ្ដោះអាសន្ន ទៅលើចំណុច “ក” ។

ឃ-មូលហេតុ ៖

-ដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.......ចុះថ្ងៃទី....ខែ.....ឆ្នាំ..... និងឈ្មោះរបស់តុលាការ...........................

-អ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ...................នៅថ្ងៃទី........ខែ.......ឆ្នាំ.........

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.....................(អាសយដ្ឋាន.................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត......................(អាសយដ្ឋាន................)

ឆ-អត្តសញ្ញាណអ្នកទិញ................................(ថ្ងៃទី.....ខែ.....ឆ្នាំ......ទីកន្លែងកំណើត ឈ្មោះឪពុកម្ដាយ អាសយដ្ឋាន ...............................................)

ឯកសារភ្ជាប់ជាមួយ៖

-ឯកសារចម្លងយថាភូត នៃដីកាសម្រេចអនុញ្ញាតឱ្យលក់

-ឯកសារថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទិញ

-ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ដែលបញ្ជាក់ថាអ្នកទិញ បានបង់ថ្លៃលក់ទៅតុលាការអនុវត្តរួចហើយ ។

## កថាភាគទី ៣

## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះ សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត

**ប្រការ ១៣ ៖** លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត ដោយផ្អែកលើកថាខណ្ឌទី ១០ នៃមាត្រា ៤០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានចុះបញ្ជីបានបង្កើតអានុភាព តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីបញ្ជាក់ថា សិទ្ធិលើបំណុលនោះត្រូវបានរឹបអូសហើយ ។

ចំពោះពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោម :

-កម្មវត្ថុនៃពាក្យសុំ

-សញ្ញាណនៃដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុល (ប្រសិនបើមាន)

-សញ្ញាណរបស់ម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃអចលនវត្ថុ ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ កូនបំណុលនៃការអនុវត្ត និងកូនបំណុលទី ៣

-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណនៃសិទ្ធិលើបំណុល ដែលម្ចាស់បំណុលទាមទារឱ្យអនុវត្តដោយបង្វិលទៅលើកូនបំណុលនៃការអនុវត្ត ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:..............................(សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.......................(លេខក្បាលដី ឬ លេខប័ណ្ណដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ...... ..........................(អាសយដ្ឋាន......................................)

គ-គោលបំណងនៃការចុះបញ្ជី..........................(ការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុចំណុច “ក”)

ឃ-មូលហេតុ....................(ដីកាសម្រេចចរឹបអូសលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....ហើយថ្ងៃទី.....ខែ.....ឆ្នាំ......ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ..................................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន.................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត...........................(អាសយដ្ឋាន.................................)

ឆ-ឈ្មោះកូនបំណុលទី ៣ ..........................(អាសយដ្ឋាន................
.......................)

ជ- សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយ:

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូស ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជី អំពីកាលបរិច្ឆេទ ដែលដីកាសម្រេចរឹបអូសនោះមានអានុភាព។

ចំពោះដីកាសម្រេចរឹបអូសខាងលើមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុលទី ៣ ។

-ឯកសារចម្លងនៃពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលមានសេចក្ដីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

**ប្រការ ១៤ : លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ដោយផ្អែកលើមាត្រា ៤០៨ មាត្រា ៤១០ និងមាត្រា ៤១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើមានពាក្យសុំឱ្យលុបការចុះបញ្ជី ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ក្នុងករណីណាមួយដូចខាងក្រោមនេះ :

- បើពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុលត្រូវបានដកវិញ ឬ
- បើដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុលមានអានុភាព ឬ
- បើតុលាការអនុវត្តបានទទួលដំណឹងពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ឬ
- បើតុលាការអនុវត្តបានទទួលដំណឹងពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការផ្ញើប្រាក់ទៅតុលាការអនុវត្តដូចជា : សញ្ញាណនៃរឿងក្ដី ឈ្មោះនាមករណ៍របស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត មូលហេតុនៃការផ្ញើចំនួនទឹកប្រាក់ដែលបានផ្ញើជាដើម ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:.........................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ......................(លេខក្បាលដី ឬ លេខប័ណ្ណ

ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលធានាសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស)

ខ-ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ.......... (អាសយដ្ឋាន .....................................................................)

គ-គោលបំណងនៃការចុះបញ្ជី..................(ការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ..........................(ការដកពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុលនៅថ្ងៃទី.......ខែ......ឆ្នាំ.......ដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុលលេខ......ចុះថ្ងៃទី......ខែ.......ឆ្នាំ.......ហើយថ្ងៃទី......ខែ......ឆ្នាំ......ដែលមានអានុភាព និងឈ្មោះរបស់តុលាការ ឬ ការសងប្រាក់ ឬ ការផ្ញើប្រាក់របស់កូនបំណុលទី ៣ ចុះថ្ងៃទី..... ខែ......ឆ្នាំ........)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន........... ...........................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត............................(អាសយដ្ឋាន.......... ...........................................)

ឆ-ឈ្មោះកូនបំណុលទី៣.......................................(អាសយដ្ឋាន.......... ...........................................)

ជ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុល ដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីមានការដកពាក្យសុំអនុវត្តចំពោះសិទ្ធិលើបំណុល :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លង យថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានអានុភាព :

ក-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ។

ខ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៣៧៥ (ការបង់សោហ៊ុយជាមុន) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

៣-ក្នុងករណីតុលាការអនុវត្តបានទទួលដំណឹងពីម្ចាស់បំណុល នៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ :

ក-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងជាលាយលក្ខណ៍អក្សរ ពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ហើយក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតជូនដំណឹងនោះ ដែលមានសេចក្ដីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងដោយផ្ទាល់មាត់ ពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ហើយក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការបានទទួលដំណឹងពីម្ចាស់បំណុលនៃការអនុវត្តនោះ ។

៤-ក្នុងករណីតុលាការអនុវត្តបានទទួលដំណឹងពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការអនុវត្ត :

ក-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងជាលាយលក្ខណ៍អក្សរ ពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតជូនដំណឹងនោះ ដែលមានសេចក្ដីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងដោយផ្ទាល់មាត់ពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការបានទទួលដំណឹងពីកូនបំណុលទី ៣ ។

**ប្រការ ១៥ : លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដោយផ្អែកលើកថាខណ្ឌទី ១០ នៃមាត្រា ៤១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើបានបញ្ចប់ការលក់ចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតរួចហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជី

ផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត និងឱ្យលុបការចុះបញ្ជីអំពីការរឹបអូសតាមពាក្យសុំរបស់អ្នកទិញ ។

ចំពោះពាក្យសុំរបស់អ្នកទិញ ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

-កម្មវត្ថុនៃពាក្យសុំ

-សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដែលត្រូវបានផ្ទេរ

-សញ្ញាណអ្នកទិញ

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណម្ចាស់អចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត

-មូលហេតុនៃការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:...................................(សរសេរអំពីខ្លឹមសារឱ្យចុះបញ្ជីផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត និងឱ្យលុបការចុះបញ្ជីអំពីការរឹបអូស)

ក-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត (លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត (អាសយដ្ឋាន.........................)

គ-គោលបំណងនៃការចុះបញ្ជី........................(ផ្ទេរហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត និងលុបការចុះបញ្ជីអំពីការរឹបអូស )

ឃ-មូលហេតុ.................(អាជ្ញាសាលាបានទទួលប្រាក់ពីការលក់ នៅថ្ងៃទី....... ខែ........ឆ្នាំ........... និងឈ្មោះរបស់តុលាការ...........................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត........................(អាសយដ្ឋាន.............. .......................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន.............. .......................................)

ឆ-ឈ្មោះកូនបំណុលទី ៣.................................(អាសយដ្ឋាន............ .......................................)

ជ-អត្តសញ្ញាណអ្នកទិញ........................................(អាសយដ្ឋាន............
........................................)

ឈ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយៈ

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលក់

-ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម នៃកំណត់ហេតុដែលបញ្ជាក់ថា អ្នកទិញបានបង់ថ្លៃលក់ទៅអាជ្ញាសាលារួចហើយ

-ឯកសារចម្លងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកទិញ ។

## កថាភាគទី ៤

## ការចុះបញ្ជីដែលពាក់ព័ន្ធនឹងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

**ប្រការ ១៦ : លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នដោយផ្អែកលើកថាខណ្ឌទី៣ និងទី ៤ នៃមាត្រា ៥៦៧ មាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

នៅពេលដែលតុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះ តាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល ។

បើដីកាសម្រេចការរឹបអូសជាបណ្តោះអាសន្នបានអនុវត្តរួចហើយ តែមានពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នថ្មីមួយទៀត ចំពោះអចលនវត្ថុដដែលនោះ ហើយតុលាការទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នថ្មីទៀត (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ចធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ តាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអាចចេញដោយតុលាការផ្សេង យោងតាមមាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:...............................(សរសេរអំពីខ្លឹមសារចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន................................)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ................. (អាសយដ្ឋាន ...................................)

គ-គោលបំណងនៃការចុះបញ្ជី................(ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននូវកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ទៅលើអចលនវត្ថុចំណុច"ក")

ឃ-មូលហេតុ...................................(ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ.......ចុះថ្ងៃទី..... ខែ.....ឆ្នាំ.......និងឈ្មោះរបស់តុលាការ...................... ។

ង-ឈ្មោះម្ចាស់បំណុល.................................(អាសយដ្ឋាន.................................................................)

ច-ឈ្មោះកូនបំណុល...................................(អាសយដ្ឋាន.................................................................)

ឯកសារភ្ជាប់ជាមួយ :

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ។

**ប្រការ ១៧ : លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ដោយផ្អែកលើកថាខណ្ឌទី៣ និងទី៤ នៃមាត្រា៥៦៧ និងមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ បើពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្នត្រូវបានដក ឬ បើដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្នបានបង្កើតអានុភាព ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ច ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននោះ ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:....................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន.................................)

ក-អត្តសញ្ញាណនៃអចលនវត្ថុ............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ...... .....................(អាសយដ្ឋាន ...............................................)

គ-គោលបំណងនៃការចុះបញ្ជី (ការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននូវកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគទៅលើអចលនវត្ថុ ចំណុច "ក")

ឃ-មូលហេតុ........................(ការដកពាក្យសុំដីកាវឹបអូសជាបណ្តោះអាសន្ន ឬការដកពាក្យសុំអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចុះថ្ងៃទី.....ខែ.......ឆ្នាំ........ ឬដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្នលេខ.....ចុះថ្ងៃទី.....ខែ......ឆ្នាំ.......ហើយថ្ងៃទី......ខែ......ឆ្នាំ.......ដែលមានអានុភាព និងឈ្មោះរបស់តុលាការ.....................)

ង-ឈ្មោះម្ចាស់បំណុល..................................(អាសយដ្ឋាន............... ...........................................................)

ច-ឈ្មោះកូនបំណុល...................................(អាសយដ្ឋាន............... ...........................................................)

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូត នៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្នត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

៣-ក្នុងករណីការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នត្រូវបានលុបចោល ៖

ក-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៩ (ការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ដោយធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ខ-ក្នុងករណីដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានលុបចោលផ្អែកលើមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) មាត្រា ៥៥៨ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារការផ្លាស់ប្ដូរស្ថានភាព) និងមាត្រា ៥៦១ (បណ្ដឹងជំទាស់) ហើយតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិ នៃគន្ថីទី ៦) និង មាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ក" ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) និងចំណុច "ឆ" កថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ឃ-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិ នៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ង" (ឯកសារចម្លងយថាភូតនៃកំណត់ហេតុសះជា ដែលមានខ្លឹមសារថា មិនអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ឬ ក៏ដកពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬដកពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ង-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី៦) មាត្រា ៣៦៤ (បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត) មាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការ

សម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច“ឆ” “ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន យោងតាមកថាខណ្ឌ ទី ២ នៃមាត្រា ៣៦៧ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរតាមមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) ឬ អនុសារសាលក្រមចុងក្រោយ នៃបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្តដែលបង្គាប់ឱ្យលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ច-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិ នៃគន្ថីទី ៦) មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) មាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) និង មាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ឆ” “ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន យោងកថាខណ្ឌទី ២ នៃមាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ា ចំពោះការទាមទារជា អាទិ៍) ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរតាម មាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) ឬអនុសារសាលក្រមចុងក្រោយនៃបណ្ដឹងតវ៉ារបស់តតិយជន ដែលបង្គាប់ឱ្យលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ឆ-ការលុបចោលដោយផ្អែកលើថាខណ្ឌទី៤ នៃមាត្រា ៥៦៧ (ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ជ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី៣ នៃមាត្រា៥៣៧ (សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

# កថាភាគទី ៥

## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត

**ប្រការ ១៨ :** លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដោយផ្អែកលើមាត្រា ៥៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បើតុលាការបានចេញដីកាសម្រេចហាមឃាត់មិនឱ្យកូនបំណុលទី ៣ សងទៅកូនបំណុលចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីបញ្ជាក់ថា សិទ្ធិលើបំណុលនោះត្រូវបានរឹបអូសជាបណ្ដោះអាសន្ន តាមពាក្យសុំរបស់ម្ចាស់បំណុល ។

ចំពោះពាក្យសុំរបស់ម្ចាស់បំណុលដូចមានចែងក្នុងកថាខណ្ឌទី ១ នេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោម :

-កម្មវត្ថុនៃពាក្យសុំ

-សញ្ញាណនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល (ប្រសិនបើមាន)

-សញ្ញាណរបស់ម្ចាស់បំណុលកម្មសិទ្ធិករនៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ កូនបំណុល និងកូនបំណុលទី ៣

-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណនៃសិទ្ធិលើបំណុលដែលនឹងត្រូវបានរក្សាការពារ

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៩ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:............................ (សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ .................. (អាសយដ្ឋាន.......................................................)



7 / 18

គ-គោលបំណងនៃការចុះបញ្ជី......................(ការរឹបអូសជាបណ្ដោះអាសន្ននូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ...................(ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុលលេខ......ថ្ងៃទី.....ខែ.....ឆ្នាំ......ហើយថ្ងៃទី.....ខែ......ឆ្នាំ.......ដែលមានអានុភាព និងឈ្មោះរបស់តុលាការ.........................................)

ង-ឈ្មោះម្ចាស់បំណុល...................................(អាសយដ្ឋាន..............
..............................................)

ច-ឈ្មោះកូនបំណុល.....................................(អាសយដ្ឋាន...............
..............................................)

ឆ-ឈ្មោះកូនបំណុលទី៣.................................(អាសយដ្ឋាន...............
..............................................)

ជ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយ:

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីអំពីកាលបរិច្ឆេទ ដែលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះមានអានុភាព ។

ចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នខាងលើ មានអានុភាពនៅពេលដែលបានបញ្ជូនទៅដល់កូនបំណុលទី ៣ ។

-ឯកសារចម្លងនៃពាក្យសុំរបស់ម្ចាស់បំណុលដែលមានសេចក្ដីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

**ប្រការ ១៩ : លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដោយផ្អែកលើកថាខណ្ឌទី ៥ នៃមាត្រា ៥៦៦ មាត្រា ៤០៨ និងមាត្រា ៤១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើមានពាក្យសុំឱ្យលុបការចុះបញ្ជី ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគ

ផ្សេងទៀត ក្នុងករណីណាមួយដូចខាងក្រោមនេះ ៖

-បើពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតត្រូវបានដក ឬ

-បើពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ត្រូវបានដក ឬ

-បើដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត បានបង្កើតអានុភាព ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ ៖

កម្មវត្ថុ:......................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលធានាសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ន)

ខ-ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ........ .................. (អាសយដ្ឋាន.................................................)

គ-គោលបំណងនៃការចុះបញ្ជី.........................(លុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុ ចំណុច“ក”)

ឃ-មូលហេតុ............. (ការដកពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ឬ ពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតនៅថ្ងៃទី......ខែ......ឆ្នាំ....... ឬដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតលេខ.....ចុះថ្ងៃទី......ខែ.....ឆ្នាំ.....ដែលមានអានុភាពនៅថ្ងៃទី.....ខែ....ឆ្នាំ...... និងឈ្មោះរបស់តុលាការ..........................)

ង-ឈ្មោះម្ចាស់បំណុល...............................(អាសយដ្ឋាន......................
..........................................)

ច-ឈ្មោះកូនបំណុល...............................(អាសយដ្ឋាន.....................
..........................................)

ឆ-ឈ្មោះកូនបំណុលទី ៣.........................(អាសយដ្ឋាន.......................
..........................................)

ជ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

៣-ក្នុងករណីការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានលុបចោល :

ក-ការលុបចោលដោយសារការធ្វើប្រាក់រំដោះអំពីការរឹបអូសជាបណ្តោះអាសន្នដោយផ្អែកលើមាត្រា ៥៦៩ (ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) “ រួមទាំងករណីដែលការធ្វើប្រាក់ដែលស្មើនឹងចំនួនប្រាក់ នៃសិទ្ធិលើបំណុលដោយកូនបំណុលទី ៣ ត្រូវចាត់ទុកថាជាការធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ដោយយោងតាមកថាខណ្ឌទី ៣ នៃមាត្រា ៥៦៦ (ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) ” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លង

យថាភូត នៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ខ-ក្នុងករណីដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវបានលុបចោល ដោយផ្អែកលើ មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) មាត្រា ៥៥៨ (ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្ដូរស្ថានភាព) និងមាត្រា ៥៦១ (បណ្ដឹងជំទាស់) ហើយតុលាការអនុវត្តរក្សាការពារចេញដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) និង មាត្រា ៣៧០ (ការផ្អាក និងការលុបចោល ការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ក” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ឆ” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ឃ-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ង” (ឯកសារចម្លងយថាភូតនៃកំណត់ហេតុសះជាដែលមានខ្លឹមសារថា មិនអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ឬ ក៏ដកពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ ដកពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ង-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី៦) មាត្រា ៣៦៤ (បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត) មាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) និង មាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ឆ” (ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន យោង

តាមមាត្រា ៣៦៧ កថាខណ្ឌទី ២ ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ តាមមាត្រា ៥៦៤ ឬ អនុសារសាលក្រម ចុងក្រោយនៃបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តដែល បង្គាប់ឱ្យលុបចោលការអនុវត្តការរឹបអូស ជាបណ្តោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែង ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

ច-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) មាត្រា ៣៦៥ (បណ្តឹងតវ៉ាបស់តតិយជន) មាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) និង មាត្រា ៣៧០ (ការផ្អាកនិងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ឆ” (ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្ត ការរឹបអូសជាបណ្តោះអាសន្ន យោងតាមមាត្រា ៣៦៧ កថាខណ្ឌទី ២ ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ តាមមាត្រា ៥៦៤ ឬ អនុសារសាលក្រមចុងក្រោយ នៃបណ្តឹងតវ៉ារបស់តតិយជន ដែលបង្គាប់ឱ្យលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

ឆ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី៤ នៃមាត្រា ៥៦៧ (ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

ជ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី៣ នៃមាត្រា ៥៣៧ (សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

# កថាភាគទី ៦
## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

**ប្រការ ២០ :** លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុដោយផ្អែកលើមាត្រា ៥៧០ មាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

នៅពេលដែលតុលាការបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងតាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល ។

បើដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុបានអនុវត្តរួចហើយ តែមានពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុដដែលថ្មីមួយទៀត ហើយតុលាការទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការត្រូវចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នថ្មីមួយទៀត (ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ច ធ្វើការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះ តាមពាក្យសុំឱ្យអនុវត្តរបស់ម្ចាស់បំណុល ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:.............................(គឺសរសេរអំពីខ្លឹមសារការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន)

ក-អត្តសញ្ញាណនៃអចលនវត្ថុ........................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ ..................... (អាសយដ្ឋាន ..........................................)

គ-គោលបំណងនៃការចុះបញ្ជី......................(ការចាត់ចែងជាបណ្ដោះអាសន្ន ចំណុច “ក” )

ឃ-មូលហេតុ....................(ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ..... ចុះថ្ងៃទី.....ខែ......ឆ្នាំ......និងឈ្មោះរបស់តុលាការ..........................)

ង-ឈ្មោះម្ចាស់បំណុល..........................(អាសយដ្ឋាន......................
.................................................................................)

ច-ឈ្មោះកូនបំណុល...............................(អាសយដ្ឋាន....................
...............................................................................)

ឯកសារភ្ជាប់ជាមួយ :

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

**ប្រការ ២១ : លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងដោយផ្អែកលើមាត្រា ៥៧០ និងមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើពាក្យសុំចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ឬបើពាក្យសុំអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុត្រូវបានដក ឬ បើដីកាសម្រេចលុបចោលការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុដែលត្រូវបានចាត់ចែងជាបណ្ដោះអាសន្ន បានបង្កើតអានុភាពក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ច ឱ្យលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុនោះ ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:....................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ...........................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ........
................ (អាសយដ្ឋាន ..................................................)

គ-គោលបំណងនៃការចុះបញ្ជី ....................................(លុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ចំណុច“ក” )

ឃ-មូលហេតុ ......................(ការដកពាក្យសុំដីកាចាត់ចែងជាបណ្ដោះអាសន្ន

ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ឬ ការដកពាក្យសុំអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុចុះថ្ងៃទី......ខែ.........ឆ្នាំ......... ឬដីកាសម្រេចលុបចោលការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុលេខ...... ចុះថ្ងៃទី.....ខែ.....ឆ្នាំ.......ហើយថ្ងៃទី......ខែ......ឆ្នាំ.......ដែលមានអានុភាព និងឈ្មោះរបស់តុលាការ...................................)

ង-ឈ្មោះម្ចាស់បំណុល..........................................(អាសយដ្ឋាន............ ..........................................................)

ច-ឈ្មោះកូនបំណុល..........................................(អាសយដ្ឋាន........... ..........................................................)

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីពាក្យសុំដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីពាក្យសុំអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

៣-ក្នុងករណីការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុត្រូវបានលុបចោល :

ក-ក្នុងករណីដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែង

អចលនវត្ថុ ត្រូវបានលុបចោលដោយផ្អែកលើមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៧ (ការលុបចាលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) មាត្រា ៥៥៨ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារការផ្លាស់ប្ដូរស្ថានភាព) មាត្រា ៥៥៩ (ការលុបចាលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដោយសារស្ថានភាពពិសេស) និង មាត្រា ៥៦១ (បណ្ដឹងជំទាស់) ហើយតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ដោយផ្អែកលើមាត្រា ៥៦៤ ( ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ)កថា-ខណ្ឌទី ១ ចំណុច "ក" ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

ខ-ការលុបចោលដោយផ្អែកលើមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារជាអាទិ៍) មាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ឆ" ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ង" (ឯកសារចម្លងយថាភូតនៃកំណត់ហេតុសះជា ដែលមានខ្លឹមសារថា មិនអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ឬ ការដកពាក្យសុំដីកាសម្រេចការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ឬ ការដកពាក្យសុំអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

ឃ-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤(ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី៦) មាត្រា ៣៦៤ (បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត) មាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) និងមាត្រា ៣៧០

(ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ឆ" (ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ យោងតាមមាត្រា ៣៦៧ កថាខណ្ឌទី ២ ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ តាមមាត្រា ៥៦៤ ឬ អនុសារសាលក្រមចុងក្រោយនៃបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ដែលបង្គាប់ឱ្យលុបចោលការចាត់ចែង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

ង-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) មាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយជាអាទិ៍ ) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ឆ" (ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុយោងតាមមាត្រា ៣៦៧ កថាខណ្ឌទី ២ ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ តាមមាត្រា ៥៦៤ ឬ អនុសារសាលក្រមចុងក្រោយ នៃបណ្ដឹងតវ៉ារបស់តតិយជនដែលបង្គាប់ឱ្យលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

ច-ការលុបចោលដោយផ្អែកលើមាត្រា ៥៧០ (ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន) មាត្រា ៥៦៧ (ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ) កថាខណ្ឌទី៤ និងមាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្ត ការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

ឆ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី៣ នៃមាត្រា ៥៣៧ (សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង ។

## ផ្នែកទី ៣
## នីតិវិធីនៃការចុះបញ្ជី
## កថាភាគទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ២២: នីតិវិធីនៃការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ**

ក-ចំពោះការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ ការរឹបអូសជាបណ្ដោះអាសន្ននូវកម្មសិទ្ធិ ការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងកម្មសិទ្ធិ ត្រូវសរសេរនៅក្នុង "សៀវភៅគោលបញ្ជីដីធ្លី " នៅក្នុងខ្ទង់(Column)ត្រង់ " បន្ទុកលើអចលនវត្ថុ " ។

ខ-ចំពោះការចុះបញ្ជីអំពីការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ការរឹបអូសជាបណ្ដោះអាសន្ននូវសិទ្ធិជួលអចិន្ត្រៃយ៍ ការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវសរសេរនៅក្នុង "សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍" នៅក្នុងខ្ទង់(Column)ត្រង់ "បន្ទុកលើអចលនវត្ថុ " ។

គ-ចំពោះការចុះបញ្ជីអំពីការរឹបអូសផលុបភោគ ការរឹបអូសជាបណ្ដោះអាសន្ន នូវផលុបភោគ ការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងផលុបភោគ ត្រូវសរសេរនៅក្នុង"សៀវភៅចុះបញ្ជីផលុបភោគ" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ។

## កថាភាគទី ២
## របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

**ប្រការ ២៣: របៀបចុះបញ្ជីអំពីការរឹបអូសក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ**

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្ដាក់ដែលបានកំណត់ក្នុងប្រការ ៧ (លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសចំពោះអចលនវត្ថុ ដោយផ្អែកលើមាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីទៅតាមប្រភេទនៃការរឹបអូស :

ក-ចំពោះការរឹបអូសកម្មសិទ្ធិត្រូវសរសេរក្នុង"សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់(Column) ត្រង់"បន្ទុកលើអចលនវត្ថុ" :

“ ត្រូវបានរឹបអូសកម្មសិទ្ធិ តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.......ចុះថ្ងៃទី .....ខែ........ឆ្នាំ.......របស់តុលាការអនុវត្ត........លវ.Aj.....(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ)” ។

ខ-ចំពោះការរឹបអូសចំណែកកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុង “សៀវភៅគោលបញ្ជីដីធ្លី” នៅក្នុងខ្ទង់ (Column) ត្រង់“បន្ទុកលើអចលនវត្ថុ” :

“ ត្រូវបានរឹបអូសចំណែកកម្មសិទ្ធិអវិភាគរបស់ឈ្មោះ............តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី.....ខែ....ឆ្នាំ......របស់តុលាការអនុវត្ត.............លវ.Aj... (ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ)” ។

គ-ចំពោះការចុះបញ្ជីអំពីការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវសរសេរក្នុង “ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” :

“ ត្រូវបានរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ..... ចុះថ្ងៃទី.....ខែ.....ឆ្នាំ......របស់តុលាការអនុវត្ត.........លវ.Aj... (ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) ” ។

ឃ-ចំពោះការចុះបញ្ជីអំពីការរឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួមត្រូវសរសេរក្នុង “សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” :

“ ត្រូវបានរឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ.....................តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ........ចុះថ្ងៃទី...ខែ...ឆ្នាំ.....របស់តុលាការអនុវត្ត........ លវ.Aj... (ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) ” ។

ង-ចំពោះការចុះបញ្ជីអំពីការរឹបអូសផលុបភោគ ត្រូវសរសេរក្នុង “សៀវភៅចុះបញ្ជីផលុប-ភោគ” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” :

“ ត្រូវបានរឹបអូសផលុបភោគតាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី .....ខែ......ឆ្នាំ.....របស់តុលាការអនុវត្ត................លវ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ ) ” ។

ច-ចំពោះការចុះបញ្ជីអំពីការរឹបអូសចំណែកផលុបភោគដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង “សៀវភៅចុះបញ្ជីផលុបភោគ” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” :

“ ត្រូវបានរឹបអូសចំណែកផលុបភោគរបស់ឈ្មោះ...........តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី.....ខែ......ឆ្នាំ........របស់តុលាការអនុវត្ត.........លរ.Aj... ( ជាទឹកក្រហម ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) ” ។

## ប្រការ ២៤ : របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្អកផ្អាក់ដែលបានកំណត់ក្នុងប្រការ ៨ (លិខិតផ្អកផ្អាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសចំពោះអចលនវត្ថុ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីអំពីការលុបទៅតាមប្រភេទនៃការរឹបអូស :

១-ចំពោះការចុះបញ្ជីអំពីការលុបការរឹបអូសកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុង “សៀវភៅគោលបញ្ជីដីធ្លី” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” ដូចគ្នានឹងការចុះបញ្ជីអំពីការ “ រឹបអូសកម្មសិទ្ធិ ឬ រឹបអូសចំណែកកម្មសិទ្ធិអវិភាគ ” ដោយត្រូវសរសេរថា :

“ ត្រូវបានលុបការរឹបអូស.......ដែលតុលាការ................បានចេញដីកាសម្រេចលេខ......ចុះថ្ងៃទី......ខែ......ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ.........ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....របស់តុលាការអនុវត្ត.........លរ.Aj... ឬតាមការដកពាក្យរបស់ម្ចាស់បំណុលនៃការអនុវត្តចុះថ្ងៃទី.....ខែ......ឆ្នាំ......(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

២-ចំពោះការចុះបញ្ជីអំពីការលុបការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិរួមត្រូវសរសេរក្នុង “សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” ដូចគ្នានឹងការចុះបញ្ជីអំពីការ “ រឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ឬ រឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ” ដោយត្រូវសរសេរថា :

“ ត្រូវបានលុបការរឹបអូស.......ដែលតុលាការ................បានចេញដីកាសម្រេចលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ......របស់តុលាការអនុវត្ត...........លរ.Aj... ឬ តាមការដកពាក្យរបស់ម្ចាស់បំណុលនៃការអនុវត្តចុះថ្ងៃទី....ខែ.....ឆ្នាំ.....(ជាទឹកខៀវ ឬ ខ្មៅ ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

៣-ចំពោះការចុះបញ្ជីអំពីការលុបការរឹបអូសផលុបភោគ ឬ ចំណែកផលុបភោគ ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីផលុបភោគ" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ " ដូចគ្នានឹងការចុះបញ្ជីអំពីការ " រឹបអូសផលុបភោគ ឬ រឹបអូសចំណែកផលុបភោគ " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការរឹបអូស......ដែលតុលាការ.......បានចេញដីកាសម្រេចលេខ..... ចុះថ្ងៃទី....ខែ......ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ.......ចុះថ្ងៃទី.....ខែ.....ឆ្នាំ..... របស់តុលាការអនុវត្ត..............លរ.Aj... ឬ តាមការដកពាក្យរបស់ម្ចាស់បំណុលនៃការអនុវត្ត ចុះថ្ងៃទី.....ខែ.....ឆ្នាំ......(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

**ប្រការ ២៥ : របៀបចុះបញ្ជីអំពីការផ្ទេរសិទ្ធិ អំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ អំពីការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្ដោះអាសន្ន អំពីការលុបការចុះបញ្ជី អំពីការការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន**

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្ដាក់ដែលបានកំណត់ក្នុងប្រការ ៩ (លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការផ្ទេរផលុបភោគ តាមការលក់ដោយបង្ខំ ដោយផ្អែកលើមាត្រា ៤៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីអំពីការផ្ទេរ ឬ ការលុបទៅតាមប្រភេទដូចខាងក្រោម :

**១-ចុះបញ្ជីអំពីការផ្ទេរសិទ្ធិ :**

ក-ចំពោះការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" :

-នៅក្នុងខ្ទង់ (Column) ត្រង់ " លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬសាលក្រមតុលាការ " ដោយត្រូវសរសេរថា :

" ត្រូវបានផ្ទេរកម្មសិទ្ធិឱ្យទៅឈ្មោះ......................តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ......... និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ..............នៅថ្ងៃទី.....ខែ.....ឆ្នាំ...... លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ " នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ " ដោយត្រូវសរសេរថា :

“ ឈ្មោះ............(គឺឈ្មោះរបស់ម្ចាស់កម្មសិទ្ធិថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ” ដោយត្រូវសរសេរថា :

“ ថ្ងៃ.....ខែ.....ឆ្នាំ......និងទីកន្លែងកំណើត(គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ម្ចាស់កម្មសិទ្ធិថ្មី )”(ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “សាវតា” ដោយត្រូវសរសេរថា :

“ ឈ្មោះ........និងឈ្មោះ.....(គឺឈ្មោះឪពុកនិងម្តាយរបស់ម្ចាស់កម្មសិទ្ធិថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ) ។

ខ-ចំពោះការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុង “ សៀវភៅគោលបញ្ជីដីធ្លី ” :

-នៅក្នុងខ្ទង់ (Column) ត្រង់ “ លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ ” ដោយត្រូវសរសេរថា :

“ ត្រូវបានផ្ទេរចំណែកកម្មសិទ្ធិអវិភាគរបស់ឈ្មោះ.........ឱ្យទៅឈ្មោះ..............តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ................ នៅថ្ងៃទី.....ខែ.....ឆ្នាំ......លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “ នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ ” ដោយត្រូវសរសេរថា :

“ ឈ្មោះ....................(គឺឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគថ្មីទាំងអស់ឡើងវិញ)(ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគចាប់ពី បីនាក់ ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរឈ្មោះតំណាងម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ ហើយត្រូវសរសេរឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) ” ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “ ថ្ងៃ ខែ ឆ្នាំ និង ទិកន្លែងកំណើត ” ដោយត្រូវសរសេរថា :

“ ថ្ងៃ......ខែ.......ឆ្នាំ.....និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មីទាំងអស់ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់តំណាងម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ ហើយសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ ) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "សាវតា" ដោយត្រូវសរសេរថា :

" ឈ្មោះ..........និងឈ្មោះ...........(គឺឈ្មោះឪពុក និងម្ដាយរបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មីទាំងអស់) (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរឈ្មោះឪពុក និងម្ដាយរបស់អ្នកតំណាងម្ចាស់កម្មសិទ្ធិអវិភាគ ហើយសរសេរឈ្មោះឪពុក និងម្ដាយរបស់ម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

គ-ចំពោះការចុះបញ្ជីអំពីការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍" :

-នៅក្នុងខ្ទង់ (Column) ត្រង់ " លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ " ដោយត្រូវសរសេរថា :

" ត្រូវបានផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ.........ឱ្យទៅឈ្មោះ..........តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ....................នៅថ្ងៃទី.....ខែ.....ឆ្នាំ.....លរ.Aj...(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ" ដោយត្រូវសរសេរថា :

" ឈ្មោះ.......(គឺឈ្មោះរបស់ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ថ្មី) " (ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុងខ្ទង់(Column)ត្រង់ " ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត " ដោយត្រូវសរសេរថា :

" ថ្ងៃ....ខែ.....ឆ្នាំ......និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ថ្មី " (ជាទឹកខៀវ ឬ ខ្មៅ) ។

- នៅក្នុងខ្ទង់ (Column)ត្រង់ "សាវតា" ដោយត្រូវសរសេរថា :

“ ឈ្មោះ...........និងឈ្មោះ............ (គឺឈ្មោះឪពុក និងម្ដាយរបស់ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ ) ។

ឃ-ចំពោះការចុះបញ្ជីអំពីការផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង“សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ” :

-នៅក្នុងខ្ទង់ (Column) ត្រង់ “ លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាល-ក្រមតុលាការ ” ដោយត្រូវសរសេរថា :

“ ត្រូវបានផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ.........ឱ្យទៅឈ្មោះ......តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ...................... នៅថ្ងៃទី......ខែ.......ឆ្នាំ......... លរ.Aj...(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

នៅក្នុងខ្ទង់ (Column) ត្រង់ “ នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ ” ដោយត្រូវសរសេរថា :

“ ឈ្មោះ...................(គឺឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួមថ្មីទាំងអស់ឡើងវិញ) (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដី ត្រូវសរសេរឈ្មោះតំណាងម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ណាម្នាក់ ហើយសរសេរឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ទាំងអស់នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) ” ។

- នៅក្នុងខ្ទង់ (Column) ត្រង់ “ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ” ដោយត្រូវសរសេរថា :

“ ថ្ងៃ.......ខែ.....ឆ្នាំ......និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់ឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួមថ្មីទាំងអស់)(ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ចាប់ពីបីនាក់ឡើងទៅ រដ្ឋបាល-សុរិយោដី ត្រូវសរសេរឈ្មោះតំណាងម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ណាម្នាក់ ហើយសរសេរឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ទាំងអស់នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) ” ។

-នៅក្នុងខ្ទង់ (Column)ត្រង់ “សាវតា” ដោយត្រូវសរសេរថា :

" ឈ្មោះ...........និងឈ្មោះ...........(គឺឈ្មោះឪពុក និងម្តាយរបស់ម្ចាស់ចំណែកសិទ្ធិផ្លូលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួមថ្មីទាំងអស់)(ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានម្ចាស់សិទ្ធិផ្លូលអចិន្ត្រៃយ៍ចាប់ពី បីនាក់ ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរឈ្មោះឪពុក និងម្តាយរបស់អ្នកតំណាងម្ចាស់សិទ្ធិផ្លូលអចិន្ត្រៃយ៍ ហើយសរសេរឈ្មោះឪពុកនិងម្តាយរបស់ម្ចាស់សិទ្ធិផ្លូលអចិន្ត្រៃយ៍ទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

ង-ចំពោះការចុះបញ្ជីអំពីការផ្ទេរផលុបភោគ ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីផលុបភោគ " :

-នៅក្នុងខ្ទង់ (Column) ត្រង់ " លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ " ដោយត្រូវសរសេរថា :

" ត្រូវបានផ្ទេរផលុបភោគរបស់ឈ្មោះ..............ឱ្យទៅឈ្មោះ...............តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ....និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ.............នៅថ្ងៃទី.....ខែ......ឆ្នាំ.......លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

- នៅក្នុងខ្ទង់(Column)ត្រង់ "នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ" ដោយត្រូវសរសេរថា :

" ឈ្មោះ.............(គឺឈ្មោះរបស់ផលុបភោគីថ្មី) " (ជាទឹកខៀវ ឬ ខ្មៅ ) ។

- នៅក្នុងខ្ទង់(Column)ត្រង់ " ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត " ដោយត្រូវសរសេរ ថា :

" ថ្ងៃ..........ខែ.......ឆ្នាំ.......និងទីកន្លែងកំណើត(គឺថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់ផលុបភោគីថ្មី) " (ជាទឹកខៀវ ឬ ខ្មៅ ) ។

- នៅក្នុងខ្ទង់ (Column)ត្រង់ "សាវតា" ដោយត្រូវសរសេរថា :

" ឈ្មោះ.............និងឈ្មោះ............(គឺឈ្មោះឪពុក និងម្តាយរបស់ផលុបភោគីថ្មី) " (ជាទឹកខៀវ ឬ ខ្មៅ) ។

ច-ចំពោះការចុះបញ្ជីអំពីការផ្ទេរចំណែកផលុបភោគដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីផលុបភោគ "

-នៅក្នុងខ្ទង់ (Column) ត្រង់ " លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រម

តុលាការ " ដោយត្រូវសរសេរថា :

" ត្រូវបានផ្ទេរចំណែកផលុបភោគរបស់ឈ្មោះ..... ឱ្យទៅឈ្មោះ.........តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ................នៅថ្ងៃទី.....ខែ.....ឆ្នាំ......លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ" ដោយត្រូវសរសេរថា :

" ឈ្មោះ.............. (គឺឈ្មោះម្ចាស់ចំណែកផលុបភោគដែលជាសិទ្ធិរួមថ្មីទាំងអស់ឡើងវិញ)(ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់ចំណែកផលុបភោគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដី ត្រូវសរសេរឈ្មោះតំណាងម្ចាស់ផលុបភោគណាម្នាក់ ហើយសរសេរឈ្មោះម្ចាស់ចំណែកផលុបភោគទាំងអស់នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) "។

-នៅក្នុងខ្ទង់ (Column) ត្រង់ " ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត " ដោយត្រូវសរសេរថា :

" ថ្ងៃ......ខែ......ឆ្នាំ.....និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ម្ចាស់ចំណែកផលុបភោគថ្មីទាំងអស់) (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណី មានឈ្មោះម្ចាស់ចំណែកផលុបភោគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដី ត្រូវសរសេរ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់តំណាងម្ចាស់ចំណែកផលុបភោគណាម្នាក់ ហើយសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតម្ចាស់ចំណែកផលុបភោគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ ) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "សាវតា" ដោយត្រូវសរសេរថា :

" ឈ្មោះ........និងឈ្មោះ.......(គឺឈ្មោះឪពុក និងម្តាយរបស់ឈ្មោះម្ចាស់ចំណែកផលុបភោគដែលជាសិទ្ធិរួមថ្មីទាំងអស់ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានម្ចាស់ចំណែកផលុបភោគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរឈ្មោះឪពុក និងម្តាយរបស់អ្នកតំណាងម្ចាស់ចំណែកផលុបភោគ ហើយសរសេរឈ្មោះឪពុក និងម្តាយរបស់ម្ចាស់ចំណែកផលុបភោគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

**២-ចុះបញ្ជីអំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបាត់បង់អានុភាពដោយការលក់ :**

-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬសិទ្ធិដែលបាត់បង់អានុភាពដោយការលក់ គឺត្រូវចុះបញ្ជីនៅក្នុងខ្ទង់ (Column) ដូចគ្នានឹងខ្ទង់ (Column) ដែលលទ្ធកម្មសិទ្ធិត្រូវបានចុះបញ្ជី ដោយត្រូវសរសេរថា :

" ត្រូវបានលុបការចុះបញ្ជីអំពី.......(ការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬហ៊ីប៉ូតែក ជាអាទិ៍) តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.......និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ............នៅថ្ងៃទី.....ខែ....ឆ្នាំ.....លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារីក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

**៣-ចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងដែលបានបាត់បង់អានុភាពដោយការលក់ :**

-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែង ដែលបានបាត់បង់អានុភាពដោយការលក់ គឺត្រូវចុះបញ្ជីនៅក្នុងខ្ទង់ (Column) ដូចគ្នានឹងខ្ទង់ ដែលការចាត់ចែងជាបណ្តោះអាសន្នត្រូវបានចុះបញ្ជី ដោយត្រូវសរសេរថា :

" ការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ត្រូវបានលុបចោលតាមដីកាសម្រេចអនុញ្ញាតឱ្យលក់ លេខ............និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ...........នៅថ្ងៃទី.....ខែ.....ឆ្នាំ.....លរ.Aj...(ជាទឹកខៀវ ឬ ខ្មៅ) " រួចបោះត្រាលេខាចារីក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកក្រហម) " ។

**៤-ចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន ។**

-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន គឺត្រូវចុះបញ្ជីនៅក្នុងខ្ទង់ (Column) ដូចគ្នានឹងខ្ទង់ (Column) ដែលការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្នត្រូវបានចុះបញ្ជី ដោយត្រូវសរសេរថា :

" ការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្នត្រូវបានលុបចោលតាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ............និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ.............នៅថ្ងៃទី.....ខែ.......ឆ្នាំ........លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារីក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " :

## កថាភាគទី ៣
## របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

**ប្រការ ២៦ :** របៀបចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ ក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្ដាក់ដែលបានកំណត់ក្នុងប្រការ ១០ (លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៤២០ មាត្រា ៥១១ និងមាត្រា ៥១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីទៅតាមប្រភេទនៃការរឹបអូស :

**ក-ចំពោះការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ** ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសកម្មសិទ្ធិតាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.........ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....(ផ្អែកលើសិទ្ធិប្រាតិភោគ)របស់តុលាការអនុវត្ត....លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកខៀវ ឬ ខ្មៅ) " ។

**ខ-ចំពោះការចុះបញ្ជីអំពីការរឹបអូសចំណែកកម្មសិទ្ធិអវិភាគ** ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ (Column)ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសចំណែកកម្មសិទ្ធិអវិភាគរបស់ឈ្មោះ...................... តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.......ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....(ផ្អែកលើសិទ្ធិប្រាតិភោគ) របស់តុលាការអនុវត្ត.....លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**គ-ចំពោះការចុះបញ្ជីអំពីការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍** ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី.....ខែ......ឆ្នាំ......(ផ្អែកលើសិទ្ធិប្រាតិភោគ) របស់តុលាការអនុវត្ត.........លរ.Aj...(ជាទឹកក្រហម)រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ)" ។

**ឃ-ចំពោះការចុះបញ្ជីអំពីការរឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើ



ᚩ Sr

អចលនវត្ថុ ” ដោយត្រូវសរសេរថា :

“ ត្រូវបានរឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ............ តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្គាប់លេខ.....ចុះថ្ងៃទី.....ខែ......ឆ្នាំ.......(ផ្អែកលើសិទ្ធិប្រាតិភោគ) របស់តុលាការអនុវត្ត........លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកខៀវ ឬ ខ្មៅ) ” ។

**ង-ចំពោះការចុះបញ្ជីអំពីការរឹបអូសផលុបភោគ** ត្រូវសរសេរក្នុង “ សៀវភៅចុះបញ្ជីផលុបភោគ ” នៅក្នុងខ្ទង់(Column)ត្រង់ “បន្ទុកលើអចលនវត្ថុ” ដោយត្រូវសរសេរថា :

“ ត្រូវបានរឹបអូសផលុបភោគតាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្គាប់លេខ.....ចុះថ្ងៃទី....ខែ....ឆ្នាំ.... (ផ្អែកលើសិទ្ធិប្រាតិភោគ)របស់តុលាការអនុវត្ត.......លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ)”។

**ច-ចំពោះការចុះបញ្ជីអំពីការរឹបអូសចំណែកផលុបភោគដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង “ សៀវភៅចុះបញ្ជីផលុបភោគ ” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” ដោយត្រូវសរសេរថា :

“ ត្រូវបានរឹបអូសចំណែកផលុបភោគរបស់ឈ្មោះ...........តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្គាប់លេខ......ចុះថ្ងៃទី...ខែ......ឆ្នាំ........(ផ្អែកលើសិទ្ធិប្រាតិភោគ) របស់តុលាការអនុវត្ត.............លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) ” ។

## ប្រការ ២៧ : របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្ដាក់ដែលបានកំណត់ក្នុងប្រការ ១១ (លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីអំពីការលុបទៅតាមប្រភេទនៃការលុបការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ :

**ក-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ** ត្រូវសរសេរក្នុង “ សៀវភៅគោលបញ្ជីដីធ្លី ” នៅក្នុងខ្ទង់ (Column) ត្រង់ “ បន្ទុកលើអចលនវត្ថុ ” ដូចគ្នានឹង ការចុះបញ្ជីអំពី “ ការរឹបអូសកម្មសិទ្ធិ ឬ ការរឹបអូសចំណែកកម្ម

សិទ្ធិអវិភាគ ” ដោយត្រូវសរសេរថា :

“ ត្រូវបានលុបការរឹបអូស...........ដែលតុលាការ............បានចេញដីកាសម្រេច លេខ....ចុះថ្ងៃទី....ខែ....ឆ្នាំ....តាមដីកាសម្រេចលុបចោលលេខ....ចុះថ្ងៃ....ខែ.....ឆ្នាំ...... របស់តុលាការអនុវត្ត...........លរ.Aj... ឬតាមការដកពាក្យរបស់ម្ចាស់បំណុល នៃការអនុវត្ត ចុះថ្ងៃទី....ខែ.....ឆ្នាំ.....(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃ ការចុះបញ្ជី (ជាទឹកក្រហម) ” ។

**ខ-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង “ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” ដូចគ្នានឹងការចុះបញ្ជីអំពី “ ការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការរឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ” ដោយត្រូវសរសេរថា :

“ ត្រូវបានលុបការរឹបអូស.........ដែលតុលាការ..............បានចេញដីកាសម្រេច លេខ.....ចុះថ្ងៃទី.....ខែ.......ឆ្នាំ.........តាមដីកាសម្រេចលុបចោលលេខ......ចុះថ្ងៃទី...... ខែ.....ឆ្នាំ.......របស់តុលាការអនុវត្ត...............លរ. Aj... ឬតាមការដកពាក្យរបស់ម្ចាស់ បំណុលនៃការអនុវត្តចុះថ្ងៃទី....ខែ.....ឆ្នាំ......“(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកក្រហម) ” ។

**គ-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសផលុបភោគ ឬចំណែកផលុបភោគ ដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង “សៀវភៅចុះបញ្ជីផលុបភោគ” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” ដូចគ្នានឹងការចុះបញ្ជីអំពី ”ការរឹបអូសផលុបភោគ ឬ ការរឹបអូសចំណែក ផលុបភោគ ” ដោយត្រូវសរសេរថា :

“ ត្រូវបានលុបការរឹបអូស.......ដែលតុលាការ................បានចេញដីកាសម្រេច លេខ.......ចុះថ្ងៃទី....ខែ.......ឆ្នាំ.......តាមដីកាសម្រេចលុបចោលលេខ.......ចុះថ្ងៃទី...... ខែ.....ឆ្នាំ......របស់តុលាការអនុវត្ត...................លរ.Aj... ឬតាមការដកពាក្យរបស់ម្ចាស់ បំណុលនៃការអនុវត្តចុះថ្ងៃទី.....ខែ......ឆ្នាំ.....(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

**ប្រការ ២៨ :** **របៀបចុះបញ្ជីអំពីការផ្ទេរសិទ្ធិ អំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ អំពីការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្ដោះអាសន្ន អំពីការលុបការចុះបញ្ជី អំពីការរឹបអូស ឬការរឹបអូសជាបណ្ដោះអាសន្ន តាមការអនុវត្តសិទ្ធិប្រាតិភោគ**

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្ដាក់ដែលបានកំណត់ក្នុងប្រការ ១២ (លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ តាមការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៨៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីអំពីការផ្ទេរ ឬការលុបទៅតាមប្រភេទដូចខាងក្រោម :

**១-ចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ :**

**ក-ចំពោះការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ** ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" :

-នៅក្នុងខ្ទង់ (Column) ត្រង់ "លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ " ដោយត្រូវសរសេរថា :

" ត្រូវបានផ្ទេរកម្មសិទ្ធិរបស់ឈ្មោះ............. ឱ្យទៅឈ្មោះ..........តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.......និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ.............. នៅថ្ងៃទី.....ខែ....ឆ្នាំ.....លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

- នៅក្នុងខ្ទង់ (Column)ត្រង់ "នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ"ដោយត្រូវសរសេរថា :

" ឈ្មោះ................(គឺឈ្មោះរបស់ម្ចាស់កម្មសិទ្ធិថ្មី) " (ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត" ដោយត្រូវសរសេរថា :

" ថ្ងៃ.......ខែ.......ឆ្នាំ......និងទីកន្លែងកំណើត(គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ម្ចាស់កម្មសិទ្ធិថ្មី) " (ជាទឹកខៀវ ឬ ខ្មៅ ) ។

- នៅក្នុងខ្ទង់ (Column) ត្រង់ "សាវតា" ដោយត្រូវសរសេរថា :

" ឈ្មោះ............និងឈ្មោះ..............(គឺឈ្មោះឪពុក និងម្ដាយរបស់ម្ចាស់កម្មសិទ្ធិថ្មី)" (ជាទឹកខៀវ ឬ ខ្មៅ) ។

**ខ-ចំពោះការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ** ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី " :

-នៅក្នុងខ្ទង់ (Column) ត្រង់ "លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ " ដោយត្រូវសរសេរថា :

" ត្រូវបានផ្ទេរចំណែកកម្មសិទ្ធិអវិភាគរបស់ឈ្មោះ...............ឱ្យទៅឈ្មោះ..............



ϟ 𝓈𝓉

តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ......និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ................ នៅថ្ងៃទី.....ខែ.....ឆ្នាំ......លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ" ដោយត្រូវសរសេរថា :

" ឈ្មោះ.............................(គឺឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគថ្មីទាំងអស់ឡើងវិញ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគចាប់ពី បី នាក់ ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរឈ្មោះតំណាងម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ ហើយត្រូវសរសេរឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

- នៅក្នុងខ្ទង់ (Column) ត្រង់ " ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត " ដោយត្រូវសរសេរថា :

" ថ្ងៃ......ខែ......ឆ្នាំ......និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មីទាំងអស់ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគចាប់ពី បី នាក់ ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើតរបស់តំណាងម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ ហើយសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "សាវតា" ដោយត្រូវសរសេរថា :

" ឈ្មោះ..............និងឈ្មោះ............... (គឺឈ្មោះឪពុក និងម្ដាយរបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មីទាំងអស់ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគចាប់ពី បី នាក់ ឡើងទៅ រដ្ឋបាលសុរិ-យោដីត្រូវសរសេរឈ្មោះឪពុក និងម្ដាយរបស់អ្នកតំណាងម្ចាស់កម្មសិទ្ធិអវិភាគ ហើយសរសេរឈ្មោះឪពុក និងម្ដាយរបស់ម្ចាស់ចំណែកអវិភាគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

**គ-ចំពោះការចុះបញ្ជីអំពីការផ្ទេរសិទ្ធិផ្លូវអចិន្ត្រៃយ៍** ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជី

សិទ្ធិជួលអចិន្ត្រៃយ៍ ” :

-នៅក្នុងខ្ទង់ (Column) ត្រង់ “លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រម តុលាការ ” ដោយត្រូវសរសេរថា :

“ ត្រូវបានផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ....................ឱ្យទៅឈ្មោះ............... តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.......និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ............... នៅថ្ងៃទី....ខែ....ឆ្នាំ.....លរ.Aj...(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ” ដោយត្រូវសរសេរថា :

“ ឈ្មោះ.....................(គឺឈ្មោះរបស់ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ” ដោយត្រូវសរសេរ ថា :

“ ថ្ងៃ......ខែ....ឆ្នាំ......និងទីកន្លែងកំណើត (គឺថ្ងៃខែឆ្នាំ ទីកន្លែងកំណើតរបស់ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុង ខ្ទង់ (Column) ត្រង់ “សាវតា” ដោយត្រូវសរសេរថា :

“ ឈ្មោះ.................និងឈ្មោះ................(គឺឈ្មោះឪពុក និងម្តាយរបស់ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ) ។

**ឃ-ចំពោះការចុះបញ្ជីអំពីការផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង “ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ” :

-នៅក្នុងខ្ទង់ (Column) ត្រង់ “លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រម តុលាការ ” ដោយត្រូវសរសេរថា :

“ ត្រូវបានផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ...............ឱ្យទៅឈ្មោះ........... តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ............. នៅថ្ងៃទី....ខែ.....ឆ្នាំ.....លរ.Aj...(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម ) ” ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ ” ដោយត្រូវ

សរសេរថា ៖

"ឈ្មោះ.........(គឺឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួមថ្មីទាំងអស់ ឡើងវិញ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ចាប់ពី បី នាក់ ឡើងទៅ រដ្ឋបាលសុរិយោដី ត្រូវសរសេរឈ្មោះតំណាងម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ណាម្នាក់ ហើយសរសេរ ឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត" ដោយត្រូវសរសេរថា ៖

" ថ្ងៃ.......ខែ.......ឆ្នាំ......និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិរួមថ្មីទាំងអស់ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ចាប់ពី បី នាក់ ឡើងទៅ រដ្ឋបាលសុរិយោដី ត្រូវសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់តំណាងម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ណាម្នាក់ ហើយសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់ម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

- នៅក្នុងខ្ទង់ (Column) ត្រង់ "សាវតា" ដោយត្រូវសរសេរថា ៖

" ឈ្មោះ............និងឈ្មោះ.......... (គឺឈ្មោះឪពុក និងម្តាយរបស់ម្ចាស់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិរួមថ្មីទាំងអស់ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ចាប់ពី បី នាក់ ឡើងទៅ រដ្ឋបាល-សុរិយោដី ត្រូវសរសេរឈ្មោះឪពុក និងម្តាយរបស់អ្នកតំណាងម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ណាម្នាក់ ហើយសរសេរ ឈ្មោះឪពុក និងម្តាយរបស់ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

**ង-ចំពោះការចុះបញ្ជីអំពីការផ្ទេរផលុបភោគ** ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីផលុបភោគ" ៖

-នៅក្នុងខ្ទង់ (Column) ត្រង់ "លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ " ដោយត្រូវសរសេរថា ៖

" ត្រូវបានផ្ទេរផលុបភោគរបស់ឈ្មោះ................ឱ្យទៅឈ្មោះ................តាម

ដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ......... និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ............... នៅថ្ងៃទី.....ខែ.....ឆ្នាំ......លរ.Aj.....(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជី (ជាទឹកក្រហម) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ" ដោយត្រូវសរសេរថា :

" ឈ្មោះ.................. (គឺឈ្មោះរបស់ផលុបភោគីថ្មី)" (ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុងខ្ទង់ (Column) ត្រង់ " ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត " ដោយត្រូវសរសេរថា :

" ថ្ងៃ........ខែ........ឆ្នាំ......និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ផលុបភោគីថ្មី) " (ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "សាវតា" ដោយត្រូវសរសេរថា :

" ឈ្មោះ...........និងឈ្មោះ.............. (គឺឈ្មោះឪពុក និងម្តាយរបស់ផលុបភោគីថ្មី)" (ជាទឹកខៀវ ឬ ខ្មៅ) ។

**ច-ចំពោះការចុះបញ្ជីអំពីការផ្ទេរចំណែកផលុបភោគដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីផលុបភោគ " :

-នៅក្នុងខ្ទង់ (Column) ត្រង់ "លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ " ដោយត្រូវសរសេរថា :

" ត្រូវបានផ្ទេរចំណែកផលុបភោគរបស់ឈ្មោះ.................ឱ្យទៅឈ្មោះ................ តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ...... និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ.............. នៅថ្ងៃទី.....ខែ.....ឆ្នាំ......លរ.Aj...(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម)" ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ" ដោយត្រូវសរសេរថា :

" ឈ្មោះ.................គឺឈ្មោះម្ចាស់ចំណែកផលុបភោគ ដែលជាសិទ្ធិរួមថ្មីទាំងអស់ឡើងវិញ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែ បើក្នុងករណីមានឈ្មោះម្ចាស់ចំណែកផលុបភោគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដី ត្រូវសរសេរឈ្មោះតំណាងម្ចាស់ផលុបភោគណាម្នាក់ ហើយសរសេរឈ្មោះម្ចាស់ចំណែក

ផលុបភោគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជី នោះ) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត" ដោយត្រូវសរសេរថា :

" ថ្ងៃ.......ខែ.......ឆ្នាំ......និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ម្ចាស់ចំណែកផលុបភោគថ្មីទាំងអស់ដែលជាសិទ្ធិរួម (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់ចំណែកផលុបភោគចាប់ពី បី នាក់ ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់តំណាងម្ចាស់ចំណែកផលុបភោគណាម្នាក់ ហើយសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតម្ចាស់ចំណែកផលុបភោគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "សាវតា" ដោយត្រូវសរសេរថា :

" ឈ្មោះ............និងឈ្មោះ...........(គឺឈ្មោះឪពុក និងម្តាយរបស់ម្ចាស់ចំណែកផលុបភោគដែលជាសិទ្ធិរួមថ្មីទាំងអស់ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានម្ចាស់ចំណែកផលុបភោគចាប់ពី បី នាក់ ឡើងទៅ រដ្ឋបាល-សុរិយោដី ត្រូវសរសេរឈ្មោះឪពុក និងម្តាយរបស់អ្នកតំណាងម្ចាស់ចំណែកផលុបភោគណាម្នាក់ ហើយសរសេរឈ្មោះឪពុក និងម្តាយរបស់ម្ចាស់ចំណែកផលុបភោគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

**២-ចុះបញ្ជីអំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបាត់បង់អានុភាពដោយការលក់ :**

ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបាត់បង់អានុភាពដោយការលក់ គឺត្រូវចុះបញ្ជីនៅក្នុងខ្ទង់ (Column) ដូចគ្នានឹងខ្ទង់ដែលលទ្ធកម្មសិទ្ធិត្រូវបានចុះបញ្ជី ដោយត្រូវសរសេរថា :

" ត្រូវបានលុបការចុះបញ្ជីអំពី....................(ការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ ហ៊ីប៉ូតែក ជាអាទិ៍) តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.......និង អ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ..............នៅថ្ងៃទី.....ខែ......ឆ្នាំ....... លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

**៣-ចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការ**

**ចាត់ចែងដែលបានបាត់បង់អានុភាពដោយការលក់ :**

ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែង ដែលបានបាត់បង់អានុភាពដោយការលក់ គឺត្រូវចុះបញ្ជីនៅក្នុងខ្ទង់ (Column) ដូចគ្នានឹងខ្ទង់ ដែលការចាត់ចែងជាបណ្តោះអាសន្នត្រូវបានចុះបញ្ជី ដោយត្រូវសរសេរថា :

" ត្រូវបានលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ..........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ...................នៅថ្ងៃទី....ខែ....ឆ្នាំ.....លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**៤-ចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន :**

ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន គឺត្រូវចុះបញ្ជីនៅក្នុងខ្ទង់ (Column) ដូចគ្នានឹងខ្ទង់ដែលការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្នត្រូវបានចុះបញ្ជី ដោយត្រូវសរសេរថា :

